ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល




# គោលនយោបាយ និងយុទ្ធសាស្ត្រ
# សុខាភិបាលជាតិ
# សម្រាប់ថែទាំសុខភាពមនុស្សចាស់

នាយកដ្ឋានការពារសុខភាព

ឆ្នាំ២០១៦

## អារម្ភកថា

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កម្ពុជាទទួលបានកំណើនយ៉ាងច្រើន នូវអាយុកាលរំពឹង ។ មួយផ្នែកធំនៃកំណើននេះ គឺបានមកពីភាពប្រសើរឡើងនៅក្នុងលទ្ធផលសុខភាព របស់ប្រជាពលរដ្ឋ ដោយសារតែការប្តេជ្ញាចិត្តផ្នែកនយោបាយខ្លាំងក្លា ដើម្បីកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធសុខាភិបាល និងការទទួលបានសេវាសុខភាពកាន់តែច្រើន រួមទាំងការអនុវត្តគម្រោងគាំពារសុខភាពសង្គមផងដែរ។ បន្ថែមពីលើនេះកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ក៏បានរួមចំណែកផងដែរដល់លទ្ធផលសុខភាពទាំងនេះក្នុងចំណោមប្រជាជនកម្ពុជា។

ជាលទ្ធផលនៃការផ្លាស់ប្តូរទាំងនេះ កម្ពុជាកំពុងតែឆ្លងកាត់ដំណាក់កាលអន្តរកាលប្រជាសាស្ត្រ និងអេពីដេមីសាស្ត្រ។ ក្នុងន័យនេះ គេសង្កេតឃើញមានកំណើនជាប្រចាំនូវភាគរយ ប្រជាជនអាយុ៦០ឆ្នាំឡើងទៅនិងកំណើននៅក្នុងសមាមាត្រជំងឺមិនឆ្លង ក្នុងចំណោមមនុស្សពេញវ័យ។

គោលនយោបាយនិងយុទ្ធសាស្ត្រនេះ គាំទ្រដល់ប្រព័ន្ធសុខាភិបាលក្នុងការអភិវឌ្ឍឆ្ពោះទៅរកប្រព័ន្ធមួយដែលមានការរួមបញ្ចូលគ្នានូវការថែទាំសុខភាពកម្រិតបឋម កម្រិតទីពីរ និងកម្រិតទីបី សម្រាប់មនុស្សចាស់។ ដើម្បីសម្រេចបានគោលដៅនេះ គេត្រូវការអនុវត្តយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែងដោយពិចារណារួមបញ្ចូលសេវាសុខភាពបន្ថែមមួយចំនួនទៀត ការបង្កើតក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍ក៏ដូចជាកៀងគរធនធានប្រតិបត្តិការឱ្យបានគ្រប់គ្រាន់។

ការពង្រឹងគំរូថែទាំនៅមូលដ្ឋាន និងនៅសហគមន៍ ដែលយកចិត្តទុកដាក់លើតម្រូវការរបស់មនុស្សចាស់ដែលរស់នៅក្នុងតំបន់ទីប្រជុំជន និងជនបទ គឺជាគន្លឹះចំពោះការថែទាំបន្តប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តបទដ្ឋាននិងនិយាមអប្បបរមា មានសារៈសំខាន់ជាសារវ័ន្ត ដើម្បីធានាប្រសិទ្ធភាពនៃយុទ្ធវិធីរួមបញ្ចូលគ្នាមួយ។

គោលនយោបាយ និងយុទ្ធសាស្ត្រនេះ គាំទ្រដល់គោលនយោបាយជាតិស្តីពី មនុស្សចាស់និងផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល របស់ក្រសួងសុខាភិបាល ក៏ដូចជាផ្អែកលើគោលនយោបាយនិងយុទ្ធសាស្ត្រលើកទីមួយស្តីពី ការថែទាំសុខភាពមនុស្សចាស់ ដែលបានបង្កើតឡើងដោយក្រសួងសុខាភិបាលកាលពីឆ្នាំ១៩៩៣ និងស្របតាមគោលដៅ និងគោលការណ៍ណែនាំអន្តរជាតិដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបាយការណ៍ពិភពលោកស្តីពីជរាភាព (WHO 2015)។

ក្រសួងសុខាភិបាល មានមោទនភាពដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់

ការថែទាំសុខភាពមនុស្សចាស់នេះ និងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីសម្រេចឱ្យបានសុខភាពកាន់តែប្រសើរសម្រាប់មនុស្សចាស់។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណដល់ក្រុមការងារនាយកដ្ឋានការពារសុខភាព មន្ត្រីរាជការក្នុងក្រសួងសុខាភិបាល តំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសុខភាពពិភពលោក ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ដែលបានចូលរួមរៀបចំបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ថែទាំសុខភាពមនុស្សចាស់នេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**មាតិកា**


អារម្ភកថា

មាតិកា

អក្សរកាត់ និងពាក្យកាត់

១- សេចក្តីផ្តើម / សាវតារ

២- ចក្ខុវិស័យ

៣- គោលបំណង និងគោលដៅនៃគោលនយោបាយ

៤- យុទ្ធសាស្ត្រ

៥- ផែនការសកម្មភាព

ក- យន្តការស្ថាប័ន

ខ- ក្របខ័ណ្ឌច្បាប់

គ- ការគាំទ្រផ្នែកហិរញ្ញវត្ថុ

ឃ- ការកសាងសមត្ថភាព

ង. ការអនុវត្តគម្រោង

៦- ការត្រួតពិនិត្យតាមដាន និងការអនុវត្ត

សន្ទានុក្រម

## អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| ADL | សកម្មភាពរស់នៅប្រចាំថ្ងៃ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBR | ការស្តារលទ្ធភាពនៅសហគមន៍ |
| CC | ក្រុមប្រឹក្សាឃុំ |
| CD/IP | ផែនការអភិវឌ្ឍន៍/វិនិយោគឃុំ |
| CDB | មូលដ្ឋានទិន្នន័យឃុំ |
| CPA | សំណុំសកម្មភាពបង្គ្រប់ |
| CSES | ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា |
| DHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាព |
| DPM | នាយកដ្ឋានការពារសុខភាព |
| ESCAP | គណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក |
| HCMC | គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព |
| HEF | មូលនិធិសមធម៌សុខភាព |
| HIS | ប្រព័ន្ធព័ត៌មានសុខាភិបាល |
| HSSP | ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល |
| IEC | ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង |
| IO | អង្គការអន្តរជាតិ |
| KAP | ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត |
| LTC | ការថែទាំរយៈពេលវែង |
| M&E | ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| MoH | ក្រសួងសុខាភិបាល |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MPA | សំណុំសកម្មភាពអប្បបរមា |
| NCD | ជំងឺមិនឆ្លង |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSPI | ការធានារ៉ាប់រងការគាំពារសង្គមជាតិ |
| OPA | សមាគមមនុស្សចាស់ |
| PRC | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មផ្លូវកាយ |
| PSC | មជ្ឈមណ្ឌលសិក្សាប្រជាជន |

| | |
|---|---|
| PwD | ជនពិការ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SEDP | ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច |
| SMART | ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ពាក់ព័ន្ធ មានពេលវេលាកំណត់ (specific, measurable, achievable, relevant, time-bound) |
| UN | អង្គការសហប្រជាជាតិ |
| VHSG | ក្រុមទ្រទ្រង់សុខភាពភូមិ |
| VHV | អ្នកស្ម័គ្រចិត្តសុខភាពភូមិ |
| WHO | អង្គការសុខភាពពិភពលោក |

## ១- សេចក្តីផ្តើម

នៅទូទាំងពិភពលោកគេបានរាយការណ៍ឱ្យដឹងថា ប្រជាជនវ័យចំណាស់និងសមាមាត្ររបស់ពួកគេ មានការកើនឡើងជាប្រចាំ។ នេះគឺជាកត្តាជោគជ័យមួយសម្រាប់សុខភាព និងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍។ ការលើកកម្ពស់លក្ខខណ្ឌរស់នៅ និងការថែទាំសុខភាព គឺកាត់បន្ថយការស្លាប់របស់កុមារ និងការស្លាប់ពីអាយុក្មេង ព្រមទាំងបង្កើនអាយុកាលរំពឹងទុក រួមជាមួយអត្រាបង្កកំណើតទាប កត្តាទាំងនេះរួមចំណែកដល់ការវិវឌ្ឍប្រជាសាស្ត្រដែលមិនធ្លាប់មានកន្លងមក ក្នុងសកលលោក។

នៅប្រទេសកម្ពុជា គេកត់សម្គាល់ឃើញមានទំនោរប្រជាសាស្ត្រស្រដៀងគ្នានេះដែរ។ ឆ្នាំ២០១៥ប្រជាជនអាយុ៦០ឆ្នាំឡើងទៅត្រូវបានប៉ាន់ស្មានថាមានចំនួន ១,៣លាននាក់ ដែលតំណាងឱ្យប្រមាណ ៨,៣% នៃប្រជាជនសរុប។ គេបានព្យាករថានៅឆ្នាំ២០៥០ ចំនួនមនុស្សនឹងកើនឡើងដល់ ៥លាននាក់ដែលតំណាងឱ្យប្រមាណ២១%នៃប្រជាជនកម្ពុជាសរុប(NIS២០១៣)។នៅក្នុងឆ្នាំ១៩៩០អាយុកាលរំពឹងទុកជាមធ្យមចំពោះស្ត្រី និងបុរសគឺប្រមាណ៦២,៦ និង៥៤,២ ហើយបានឡើងដល់៧០,១ឆ្នាំ ចំពោះស្ត្រីនិង ៦៧,១ឆ្នាំចំពោះបុរស ត្រឹមឆ្នាំ២០១៣(NIS២០១៣)។

ចំនួននេះបង្ហាញពីសក្តានុពលសម្រាប់តួនាទីយ៉ាងសកម្ម និងប្រកបដោយផលិតភាពរបស់មនុស្សចាស់នៅប្រទេសកម្ពុជា។ នេះជាតួនាទីដែលប្រជាជនកម្ពុជាវ័យចំណាស់ជាច្រើន បានទទួលយករួចទៅហើយ ដោយហេតុថា ប្រជាជនប្រមាណជាងមួយភាគបីនៃប្រជាជនអាយុ៦០ឆ្នាំ កំពុងតែចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច (2005, J Knodel et al.)។

ទោះបីជាយ៉ាងណាក្តី នៅខណៈដែលប្រជាជនកាន់តែចូលវ័យចំណាស់ ភាពងាយរងគ្រោះរបស់ពួកគេក៏កាន់តែកើនឡើងដែរ។ ពួកគេប្រឈមមុខកាន់តែច្រើនទៅនឹងកត្តាប្រឈមផ្នែកសង្គម សេដ្ឋកិច្ច និងសុខភាព ដូចជាភាពមេម៉ាយ ផលិតភាពចុះទាប និងស្ថានភាពសុខភាពផុយស្រួយ។ បន្ថែមពីលើនេះប្រជាជនកម្ពុជាវ័យចំណាស់ប្រឈមមុខនឹងការផ្លាស់ប្តូរយ៉ាងរហ័សនៅក្នុងសង្គមផងដែរ។ ចំណាកស្រុកមកកាន់ទីក្រុង ដើម្បីស្វែងរកមុខរបរនិងការងារចំពោះមនុស្សវ័យក្មេង ធ្វើឱ្យមនុស្សចាស់កាន់តែច្រើន លែងទទួលបានការថែទាំតាមប្រពៃណីដោយកូនរបស់ពួកគេ មិនតែប៉ុណ្ណោះមនុស្សចាស់ជាច្រើន ត្រូវទទួលភារៈថែទាំចៅរបស់ពួកគេថែមទៀត។

តាមទស្សនវិស័យសុខភាពជាធម្មតា ជរាភាពត្រូវបានសម្គាល់ដោយៈ កម្សោយជាទូទៅនៅក្នុងមុខងាររាងកាយ ភាពងាយរងគ្រោះកាន់តែច្រើនទៅ នឹងកត្តាប្រឈមផ្នែកបរិស្ថាន និងភាពប្រឈមមុខកាន់តែច្រើន ទៅនិងការមានជំងឺ និងការស្លាប់រួមបញ្ចូលទាំងកម្សោយផ្នែកគំហើញ ការស្តាប់ ចលនាបំលាស់ទី សតិបញ្ញា និងផ្លូវចិត្ត។ បញ្ហានេះអាចរួមមានប្រព័ន្ធការពាររាងកាយចុះខ្សោយទប់ទល់នឹងជំងឺផ្សេងៗ ដូចជាងាយរងគ្រោះដោយសារជំងឺផ្តាសាយ និងជំងឺមិនឆ្លងកាន់តែច្រើនដូចជាជំងឺលើសឈាម ជំងឺទឹកនោមផ្អែមប្រភេទទី២ រោគពុកឆ្អឹង មហារីក និងរោគភ្លេចភ្លាំង។ ជាផលវិបាកតម្រូវការសម្រាប់សេវាបង្ការ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងការព្យាបាលសម្រន់សម្រាប់មនុស្សចាស់ ក៏កំពុងតែកើនឡើងផងដែរ។

អង្គការសុខភាពពិភពលោក កំណត់និយមន័យសុខភាពថាជា "ស្ថានភាពនៃសុខុមាលភាពពេញលេញផ្នែកផ្លូវកាយ ផ្លូវចិត្ត និងសង្គម មិនត្រឹមតែភាពគ្មានជំងឺ ឬទុ្រឌទ្រោមនោះឡើយ"។ និយមន័យនេះរំលេចពីសារៈសំខាន់នៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដែលប្រើប្រាស់ប្រសិទ្ធភាពបន្ថែមពីកិច្ចសហការពហុវិ

ស័យដើម្បីធានាថា ប្រជាជនទទួលបានដំណើរការជរាភាពប្រកបដោយផាសុកភាពបំផុត តាមរយៈសេវាបង្ការ ថែទាំ និងគាំទ្រគ្រប់គ្រាន់។ ការថែទាំបន្តបែបនេះជួយមនុស្សចាស់ ឱ្យរក្សាបានសុខភាពល្អ ទទួលបានអត្ថប្រយោជន៍ ពីការថែទាំសុខភាពដែលមានគុណភាពនៅពេលណាពួកគេត្រូវការ និងទទួលបានជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរ។ បន្ថែមពីលើនេះ ដោយសារតែស្ថានភាពសុខភាពរបស់មនុស្សចាស់ រងឥទ្ធិពលខ្លាំងដោយកត្តានានាកាលពីវ័យកុមារភាព យុវវ័យ និងមជ្ឈឹមវ័យ ពួកគេនឹងទទួលបានជរាភាពប្រកបដោយសុខភាពល្អបំផុត នៅពេលពួកគេប្រកាន់យកវិធីសាស្ត្រខ្សែជីវិត (life course approach)។ កម្ពុជាផ្តល់តម្លៃដល់ប្រជាជនវ័យចំណាស់របស់ខ្លួន និងសារៈសំខាន់នៃការអនុញ្ញាតឱ្យមាន ដំណើរការជរាភាពប្រដោយសុខភាពល្អ។ ដូច្នេះប្រទេសនេះអនុវត្តតាមការណែនាំរបស់ក្របខ័ណ្ឌអន្តរជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធដែលការពារដល់សុខុមាលភាពរបស់មនុស្សចាស់។ ក្របខ័ណ្ឌទាំងនេះរួមមាន៖ *សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិមនុស្ស(១៩៤៨) អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (២០០៦) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០ (ឧទា. គោលដៅ ១, ៣, ៥, ១០ ស្តីពី ភាពក្រីក្រ សុខភាពនិងសុខុមាលភាព សមភាពយេនឌ័រ និងការកាត់បន្ថយវិសមភាព) សេចក្តីប្រកាសនយោបាយរបស់អង្គការសហប្រជាជាតិ និងផែនការសកម្មភាពអន្តរជាតិ ក្រុងម៉ាឌ្រីដ ស្តីពីមនុស្សចាស់(២០០២) របាយការណ៍ពិភពលោកស្តីពីជរាភាព និងសុខភាព (២០១៥) សមាគមប្រ ជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)៖ ជំរុញឆ្ពោះទៅមុខរួមគ្នា (២០១៥) សេចក្តីប្រកាសស្តីពី ការពង្រឹងការគាំពារសុខភាពសង្គម(២០១៤) អាស៊ានសេចក្តីប្រកាសក្រុងដារូសាឡឹមរបស់អាស៊ានស្តីពី ស្ថាប័នគ្រួសារៈការថែទាំសម្រាប់មនុស្សចាស់ (២០១០) គណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គម នៃអង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក(ESCAP) យុទ្ធសាស្ត្រក្រុងអ៊ីសឆុន(Ischeon Strategy) "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" (២០១២) និងក្របខ័ណ្ឌថ្នាក់តំបន់សម្រាប់សកម្មភាពស្តីពី ជរាភាព និងសុខភាពនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច(២០១៤-២០១៩)ដោយអង្គការសុខភាពពិភពលោក(WHO)។ ក្របខ័ណ្ឌទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងបន្ថែមនៅក្នុងក្របខ័ណ្ឌច្បាប់ជាតិរបស់ខ្លួន រួមទាំងយុទ្ធសាស្ត្រចតុ កោណដំណាក់កាលទី៣ (២០១៣) ដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) គោលនយោបាយជាតិកម្ពុជា ស្តីពីប្រជាជន(២០០៣រាជរដ្ឋាភិបាលកម្ពុជា)ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ដោយ រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីរបបសន្តិសុខសង្គម(២០០២)រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីការការពារសិទ្ធិជនពិការ(២០០៩រាជរដ្ឋាភិបាលកម្ពុជា)និងជាក់លាក់ជាងនេះទៀតគឺ គោលនយោបាយជាតិសម្រាប់មនុស្សចាស់(២០០៣) ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា (MoSVY) និងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់ការថែទាំសុខភាពមនុស្សចាស់ (១៩៩៩) ដោយក្រសួងសុខាភិបាលដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយគោលនយោបាយបច្ចុប្បន្ននេះ។*

តាមរយៈក្របខ័ណ្ឌទាំងនេះរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានណែនាំឱ្យជំរុញការបង្កើតបរិយាកាសដែលសមស្របទៅតាមវ័យ ក្នុងនោះប្រព័ន្ធសុខាភិបាល ការពារសុវត្ថិភាពដល់សមត្ថភាពខាងក្នុង និងសមត្ថភាពផ្នែកមុខងារ តាមរយៈអន្តរាគមន៍សុខភាព ប្រកបដោយប្រសិទ្ធភាព។

គោលនយោបាយនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ព្រមទាំងពិចារណាពីទំនោរសង្គម-សេដ្ឋកិច្ច និងប្រជាសាស្ត្រដើម្បីគាំទ្រដល់ការបង្កើតឡើងនូវ ប្រព័ន្ធសុខាភិបាលមួយ

ដែលឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងតម្រូវការផ្នែកសុខភាពរបស់ប្រជាជនកម្ពុជាវ័យចំណាស់ និង លើកកម្ពស់បរិយាកាសដែលសមស្របតាមវ័យ ដែលក្នុងនោះមនុស្សចាស់អាចរស់នៅប្រកបដោយផាសុកភាព ព្រមទាំងដឹកនាំជីវិតរបស់ខ្លួនដែលសកម្ម និងប្រកបដោយសេចក្តីថ្លៃថ្នូរ។

## ២-ចក្ខុវិស័យ

ប្រជាជនកម្ពុជាវ័យចំណាស់ ទទួលបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ពី កញ្ចប់សេវាសុខភាពប្រកបដោយគុណភាព សំដៅលើកកម្ពស់ជរាភាពដែលមានផាសុកភាព សកម្ម ផលិតភាព និងសេចក្តី ថ្លៃថ្នូរ។

## ៣-គោលបំណង និងគោលដៅជាក់លាក់

### ៣-១ គោលបំណង

ដើម្បីលើកកម្ពស់ជរាភាពប្រកបដោយសុខភាពល្អ ផ្អែកលើវិធីសាស្ត្រខ្សែជីវិតរួម អន្តរវិស័យ ដែលមាន៖

-ការបង្ការ

-ការថែទាំ និង

-សេវាគាំទ្រដោយគ្រប់គ្រាន់។

ដើម្បីបង្កើតប្រព័ន្ធសុខាភិបាលមួយ ដែលអាចប្រើបាននិងឆ្លើយតបនឹងតម្រូវការ និងមានកញ្ចប់សេវាថែទាំសុខភាពរួមបញ្ចូលសម្រាប់មនុស្សចាស់រួមទាំង៖

-ការបង្ការ

-ការព្យាបាល

-ការស្តារលទ្ធភាពពលកម្ម និង

-សេវាថែទាំសម្រន់។

### ៣-២ គោលនយោបាយ

-ផ្តល់ព័ត៌មាន និងផ្សព្វផ្សាយអំពីសារៈសំខាន់តម្រូវការ និងអត្ថប្រយោជន៍នៃការលើកកម្ពស់ជរាភាពដែលមានសុខភាពល្អ

-លើកកម្ពស់កិច្ចសហការពហុវិស័យដើម្បីជរាភាព ដែលមានសុខភាពល្អនៅគ្រប់កម្រិត

-ពង្រឹងសមត្ថភាពរបស់ប្រព័ន្ធសុខាភិបាល ដើម្បីផ្តល់ការថែទាំសុខភាពបឋម កម្រិតទីពីរនិងកំរិតទីបីសម្រាប់មនុស្សចាស់។

-ជំរុញការទទួលបាន និងការប្រើប្រាស់ប្រកបដោយសមធម៌នូវ ការថែទាំជាសារវ័ន្តនិងមានគុណភាពសម្រាប់មនុស្សចាស់។

### ៣-៣ គោលដៅ

ដើម្បីស្វែងរកការគាំទ្រ និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកតាក់តែងគោលនយោបាយ អំពីជរាភាពដែលមានសុខភាពល្អ

-ដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិធានការជាមូលដ្ឋាន សម្រាប់ជរាភាពប្រកបដោយសុខភាពល្អក្នុងចំណោមប្រជាជន និងជាពិសេសក្នុងចំណោមមនុស្សចាស់ អ្នកថែទាំ និងអ្នកផ្តល់សេវា

-ដើម្បីលើកកម្ពស់បរិយាកាសសម្របតាមវ័យ តាមរយៈកិច្ចសហការអន្តរវិស័យ ដោយផ្តោតលើសេវា

បង្ការ ថែទាំ និងគាំទ្រ

-ដើម្បីពង្រឹងប្រព័ន្ធសុខាភិបាល ដើម្បីបំពេញតម្រូវការសុខភាពរបស់មនុស្សចាស់ តាមរយៈយុទ្ធវិធីរួមបញ្ចូលគ្នា ដែលរួមមានសេវាបង្ការ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងថែទាំសម្រន់គ្រប់គ្រាន់នៅគ្រប់កម្រិត

-ដើម្បីជំរុញការទទួលបាន និងការប្រើប្រាស់ប្រកបដោយសមធម៌ នូវកញ្ចប់ជាសារវ័ន្តនៃសេវាបង្ការព្យាបាល ស្តារលទ្ធភាពពលកម្ម និងសម្រន់ប្រកបដោយបរិយាប័ន្នសម្រាប់មនុស្សចាស់។

ដើម្បីជំរុញការស្រាវជ្រាវនិងគ្រប់គ្រងព័ត៌មាន ដើម្បីណែនាំដល់ការពិនិត្យឡើងវិញនិងកែសម្រួលគោលនយោបាយឆ្ពោះទៅរកអន្តរាគមន៍ ដែលមានប្រសិទ្ធភាពខ្ពស់បំផុត។

## ៤-យុទ្ធសាស្ត្រ

ធានាការទទួលបានប្រកបដោយសមធម៌នូវ ការថែទាំសុខភាពជាបន្តប្រកបដោយគុណភាព តាមរយៈប្រព័ន្ធមួយដែលឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់បានគ្រប់គ្រាន់

១-លើកកម្ពស់ការស្វែងរកការគាំទ្រផ្សព្វផ្សាយ និងចែករំលែកព័ត៌មានសំដៅដាក់បញ្ចូលបញ្ហាសុខភាពរបស់មនុស្សចាស់នៅគ្រប់កម្រិតថ្នាក់។

២-ជំរុញសហប្រតិបត្តិការពហុវិស័យនិងភាពជាដៃគូរវាងវិស័យសាធារណៈ ឯកជន ឆ្ពោះទៅរកសមាហរណកម្មការផ្តល់សេវាសុខភាពសម្រាប់មនុស្សចាស់ទៅក្នុងការថែទាំបន្ត។

៣-ពង្រឹងប្រព័ន្ធសុខាភិបាលដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពរបស់មនុស្សចាស់

ក-ការផ្តល់សេវាគ្រប់គ្រាន់

ខ-បទដ្ឋាន និងនិយាម ការទទួលស្គាល់គុណភាព

គ-ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

៤-ការសិក្សាស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង។

៥-ការអភិវឌ្ឍធនធានមនុស្ស។

៦-គម្រោងគាំពារសង្គម។

## ៤-១ គោលដៅជាយុទ្ធសាស្ត្រ

៤-១-១ លើកកម្ពស់ការស្វែងរកការគាំទ្រ ផ្សព្វផ្សាយនិងចែករំលែកព័ត៌មាន សំដៅដាក់បញ្ចូលបញ្ហារបស់មនុស្សចាស់នៅគ្រប់កម្រិតថ្នាក់

ផ្សព្វផ្សាយសារសមស្របអំពីតម្រូវការរបស់មនុស្សចាស់ និងអំពីការរួមចំណែកជាក់ស្តែងនិងក្នុងពេលខាងមុខរបស់មនុស្សចាស់នៅផ្ទះក៏ដូចជាក្នុងសង្គម។ សារត្រូវលើកកម្ពស់ជរាភាពប្រកបដោយ ផាសុកភាព និងការបង្ការជំងឺតាមរយៈ (១)ការប្រកាន់យកទស្សនវិស័យនៃជរាភាព ប្រកបដោយផាសុកភាពនិង (២)ដោះស្រាយតម្រូវការនិងផ្តល់អន្តរាគមន៍ជាក់លាក់សម្រាប់មនុស្សចាស់។ សារទាំងនេះត្រូវផ្អែកលើបទដ្ឋានវប្បធម៌ និងប្រពៃណីចំពោះការថែទាំបីបាច់មនុស្សចាស់ ហើយត្រូវដាក់បញ្ចូលអត្ថន័យដែលផ្តោតលើ៖ (១)មនុស្សក្មេងៗ ឧទាហរណ៍ តាមរយៈការដាក់បញ្ចូលសារនៅក្នុងកម្មវិធីសិក្សារបស់សាលា (២)មនុស្សពេញវ័យ ឧទាហរណ៍តាមរយៈការដាក់បញ្ចូលសារអំពីសារៈសំខាន់នៃសកម្មភាពរាងកាយនិង (៣)មនុស្សចាស់ខ្លួនឯងផ្ទាល់ តាមរយៈសារអំពីវិធីគ្រប់គ្រងរបបអាហារដែល

មានតុល្យភាព។ សារដែលផ្តោតគោលដៅលើអ្នកតាក់តែងគោលនយោបាយថ្នាក់ខ្ពស់ អ្នកគ្រប់គ្រងសុខភាពដៃគូសុខាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត នឹងលើកកម្ពស់ស្ថានភាពនៃបញ្ហារបស់មនុស្សចាស់នៅក្នុងផែនការ និងកម្មវិធីនានានៅគ្រប់កម្រិត

-ផ្សព្វផ្សាយនិងបង្កើនការយល់ដឹង ដើម្បីដាក់បញ្ចូលបញ្ហារបស់មនុស្សចាស់ ទៅក្នុងផែនការនិងកម្មវិធីនៅគ្រប់កម្រិតថ្នាក់

-ណែនាំវិធីសាស្ត្រខ្សែជីវិត (life course approach) ចំពោះជរាភាពដែលមានសុខភាពល្អ និងការបង្ការជំងឺតាមរយៈការដាក់បញ្ចូលសារអប់រំសម្រាប់មនុស្សចាស់ អ្នកថែទាំ និងអ្នកផ្តល់សេវាសុខភាព រួមទាំងសារៈសំខាន់នៃសកម្មភាពផ្លូវកាយ អនាម័យ របបអាហារដែលមានតុល្យភាព ព្រមទាំងរបបសន្តិសុខសង្គមដែលមានស្រាប់។

*<u>ចំណុចដៅ៖</u>*

*-ការយល់ដឹងកាន់តែប្រសើរ អំពីវិធានការជាមូលដ្ឋានសម្រាប់ជរាភាព ដែលមានសុខភាពល្អនៅក្នុងចំណោមមនុស្សចាស់ អ្នកថែទាំ សង្គមស៊ីវិល អ្នកផ្តល់សេវាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងអាជ្ញាធររដ្ឋាភិបាល*

*-បញ្ហាសុខភាពសំខាន់ៗរបស់មនុស្សចាស់ ត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងផែនការសុខភាពដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្រោមជាតិ ឧទា.ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ផែនការអភិវឌ្ឍន៍និងវិនិយោគឃុំ។*

៤-១-២ជំរុញភាពជាដៃគូពហុវិស័យនិងរវាងវិស័យសាធារណៈឯកជន ដើម្បីធានាសេវាសុខភាពគ្រប់ជ្រុងជ្រោយសម្រាប់មនុស្សចាស់ ទៅក្នុងការថែទាំបន្តដំណើរការជរាភាព ដែលមានសុខភាពល្អត្រូវការអន្តរាគមន៍ល្អលើសពីប្រព័ន្ធសុខាភិបាល តាមប្រពៃណីកន្លងមក។ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូពហុវិស័យ និងរវាងវិស័យសាធារណៈនិងឯកជន ដើម្បីធានាការថែទាំជាបន្តប្រកបដោយប្រសិទ្ធភាពបំផុត សម្រាប់មនុស្សចាស់។ នៅថ្នាក់ខ្ពស់ គេត្រូវការកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់ ដែលជាគណៈកម្មាធិការពហុវិស័យក្រោមឆ័ត្ររបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ដើម្បីជួយសម្រួលដល់ការសម្របសម្រួលនិងសហប្រតិបត្តិការពហុវិស័យក្នុងចំណោមក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធ។ បន្ថែមពីលើនេះគេគួរព្យាយាមស្វែងរកឱកាសពង្រីកកិច្ចសហការជាមួយវិស័យឯកជន ដើម្បីបំពេញបន្ថែម និងគាំទ្រដល់ប្រព័ន្ធសេវាសាធារណៈដោយមានអន្តរាគមន៍សុខភាពនៅថ្នាក់សហគមន៍ដូចជា៖

-សកម្មភាពអប់រំសុខភាព បង្ការជំងឺ ពិនិត្យជំងឺ ការថែទាំតាមផ្ទះ ការស្តារលទ្ធភាពពលកម្មនៅសហគមន៍និងការតាមដានការព្យាបាលសម្រាប់ជំងឺរ៉ាំរ៉ៃមួយចំនួន ឧទាហរណ៍ ជំងឺលើសឈាម និងជំងឺទឹកនោមផ្អែមប្រភេទទី២ជាដើម

-រួមចំណែកដល់ការថែទាំបន្តប្រកបដោយគុណភាព ដោយមានការសម្របសម្រួលដើម្បីជំរុញជរាភាពប្រកបដោយសុខភាពល្អ នៅក្នុងបរិយាកាសដែលសមស្របតាមវ័យ

-ពង្រឹងការសម្របសម្រួលជាមួយអ្នកផ្តល់សេវាសាធារណៈ និងឯកជន ក៏ដូចជាសង្គមស៊ីវិលក្នុងការបង្ការការថែទាំ និងការគាំទ្រសេវាសុខភាពសម្រាប់មនុស្សចាស់។

*ចំណុចដៅ៖*

*-ការគាំទ្រថ្នាក់ខ្ពស់ត្រូវបានបង្កើនដើម្បីពង្រឹង ការថែទាំសុខភាពមនុស្សចាស់ជាបន្ត ឧទាហរណ៍ ការដាក់បញ្ចូលបញ្ហាសុខភាពមនុស្សចាស់ ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងថ្នាក់ក្រោមជាតិ។ សកម្មភាព និងថវិកាលើអន្តរាគមន៍សុខភាពមនុស្សចាស់ ត្រូវបានរៀបចំឡើងតាមរយៈ ផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំ*

*-កិច្ចសហការរវាងវិស័យសាធារណៈ ឯកជន នៅថ្នាក់សហគមន៍ត្រូវបានពង្រឹង សម្រាប់អ្នកផ្តល់សេវាដែលគិតកម្រៃ និងមិនគិតកម្រៃរួមទាំងសង្គមស៊ីវិល (ឧទា.សមាគមមនុស្សចាស់ ការគាំទ្រមិត្តអ្នកស្ម័គ្រចិត្តសុខភាពភូមិ) និងក្រុមសាសនា(ឧទា. វត្តអារាម) ដែលធ្វើការដើម្បីលើកកម្ពស់សុខភាពនិងសុខុមាលភាពមនុស្សចាស់ (ឧទា.សកម្មភាពផ្លូវកាយការពិនិត្យរកជំងឺ ការថែទាំតាមផ្ទះ ការតាមដានមើលការព្យាបាល)។*

៤-១-៣ ពង្រឹងប្រព័ន្ធសុខាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពរបស់មនុស្សចាស់៖

ក-សេវាសុខភាពគ្រប់គ្រាន់សម្រាប់មនុស្សចាស់ ប្រជាជនវ័យចំណាស់ត្រូវបានអមដោយការប្រឈមនឹងហានិភ័យសុខភាព និងការធ្លាក់ចុះផ្នែកជីវសាស្ត្រ នៅក្នុងរចនាសម្ព័ន្ធនិងមុខងារនៃប្រព័ន្ធសរីរាង្គផ្សេងៗ ដែលធ្វើឱ្យមនុស្សចាស់ងាយរងគ្រោះទៅនឹងបន្ទុកជំងឺធំៗ ដែលក្នុងករណីខ្លះតម្រូវឱ្យមានការថែទាំរយៈពេលវែង។ អ្នកផ្តល់សេវាសុខភាព ត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ចូលសេវានានា ដែលឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការសុខភាពរបស់មនុស្សចាស់ឧទាហរណ៍ ការថែទាំធ្មេញ ការថែទាំភ្នែក សេវាសុខភាពផ្លូវចិត្ត និងការថែទាំរយៈពេលវែង។

-ដើម្បីពង្រឹងសេវាថែទាំសុខភាព ប្រកបដោយប្រសិទ្ធភាពដល់មនុស្សចាស់ ដោយដាក់បញ្ចូលសេវាបង្ការ ថែទាំ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងការថែទាំសម្រន់គ្រប់គ្រាន់ទៅ ក្នុងប្រព័ន្ធផ្តល់សេវាសុខភាពនៅគ្រប់កម្រិត

-ដើម្បីធានាថា មូលដ្ឋានសុខាភិបាលមានបុគ្គលិក ឱសថ សម្ភារៈបរិក្ខារគ្រប់គ្រាន់ សម្រាប់ផ្តល់សេវាថែទាំសុខភាពដល់មនុស្សចាស់ ដើម្បីបំពេញតម្រូវការសុខភាពរបស់មនុស្សចាស់ រួមទាំងសម្រាប់ការបង្ការនិងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ កម្សោយ និងការថែទាំរយៈពេលវែង។

*ចំណុចដៅ៖*

*-ការថែទាំសុខភាពមនុស្សចាស់គ្រប់គ្រាន់ ត្រូវបានដាក់បញ្ចូលក្នុងកញ្ចប់សេវា MPA និង CPA ដែលមានស្រាប់ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់*

*-មជ្ឈមណ្ឌលឧត្តមភាពជាតិមួយដែលផ្តល់ជាមូលដ្ឋានសម្រាប់សុខភាពមនុស្សចាស់ និងមានតួនាទីផ្តល់ការបណ្តុះបណ្តាលមូលដ្ឋាន និងបន្តសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅគ្រប់កម្រិតថ្នាក់ ក៏ដូចជាគាំទ្រដល់ការស្រាវជ្រាវ ការចែករំលែកព័ត៌មាន និងការតាក់តែងអនុសាសន៍សម្រាប់សេវាសុខភាពមនុស្សចាស់ ប្រកបដោយប្រសិទ្ធភាពបំផុត និងការអភិវឌ្ឍគោលនយោបាយ*

*-វេជ្ជបណ្ឌិតម្នាក់ និងគិលានុបដ្ឋាកម្នាក់ ដើរតួនាទីជាជនបង្គោលសម្រាប់ថែទាំសុខភាពមនុស្សចាស់នៅថ្នាក់មន្ទីរពេទ្យខេត្ត (សេវាជំងឺក្នុង និងជំងឺក្រៅ) ដើម្បីជួយសម្រួលដល់ការតភ្ជាប់ទៅនឹងប្រភេទ*

*ផ្សេងៗ នៃសេវាដែលត្រូវការ*

*-មូលដ្ឋានសុខាភិបាលទាំងអស់មានបុគ្គលិកនិងបរិក្ខារគ្រប់គ្រាន់ ដើម្បីផ្តល់សេវាសុខភាពជាមូលដ្ឋានដល់មនុស្សចាស់ រួមទាំងការបញ្ជូននិងការតាមដានបន្ត។*

ខ-បទដ្ឋាន និងនិយាម

ប្រសិទ្ធភាពនៃសេវាត្រូវការការធានាគុណភាពនៃសេវាដែលផ្តល់ និងការទទួលសេវាការអភិវឌ្ឍបទដ្ឋាននិងនិយាមគឺសំខាន់បំផុតចំពោះគោលដៅនេះ។ បទដ្ឋាននិងនិយាមទាំងនេះនឹងណែនាំត្រួតពិនិត្យតាមដាននិងពង្រឹងការគ្រប់គ្រងសេវាសុខភាព និងធានាសុវត្ថិភាពអ្នកប្រើប្រាស់តាមរយៈប្រព័ន្ធសេវាសុខភាពនិងរចនាសម្ព័ន្ធគាំទ្រពាក់ព័ន្ធនៅ ក្នុងគ្រឹះស្ថានសុខាភិបាលប្រភេទផ្សេងៗ ដើម្បីផ្តល់សេវាប្រកបដោយគុណភាពនិងសុវត្ថិភាពដល់ប្រជាពលរដ្ឋ។

-ដើម្បីអភិវឌ្ឍ អនុម័ត និងអនុវត្តបទដ្ឋាន និងនិយាមស្តីពី ការថែទាំសុខភាពមនុស្សចាស់គ្រប់ជ្រុងជ្រោយ រួមទាំងការអភិវឌ្ឍធនធានមនុស្ស សេវាថែទាំសុខភាព ការបញ្ជូន និងការតាមដានជាមួយសេវាពាក់ព័ន្ធ (ឧទា. សង្គម ស្តារលទ្ធភាពពលកម្ម)។

<u>*ចំណុចដៅ៖*</u>

*-បទដ្ឋាននិងនិយាមត្រូវបានបង្កើតឡើង អនុម័ត និងអនុវត្ត ផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សសេវាសុខភាពនិងដំណើរការបញ្ជូនស្របតាមគោលនយោបាយ និងគោលការណ៍ណែនាំអន្តរវិស័យពាក់ព័ន្ធដែលមានស្រាប់ (ឧទា.ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជនពិការ គោលនយោបាយជាតិស្តីពីមនុស្សចាស់ MoSVY)។*

គ-ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ (M&E)

ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើតភ័ស្តុតាងដើម្បីវាយតម្លៃអន្តរាគមន៍នានា ដែលលើកកម្ពស់ជរាភាពប្រកបដោយសុខភាពល្អ។ សកម្មភាពនេះអនុញ្ញាតឱ្យមានការតាមដានមើលការអនុវត្ត និងលទ្ធផលជាលក្ខណៈប្រព័ន្ធ ព្រមទាំងវាស់វែងប្រសិទ្ធភាពរបស់កម្មវិធី។ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ជួយអ្នកគ្រប់គ្រង អ្នកធ្វើផែនការ អ្នកអនុវត្ត អ្នកតាក់តែងគោលនយោបាយ និងម្ចាស់ជំនួយ ទទួលបានព័ត៌មានដើម្បីធ្វើការសម្រេចចិត្តអំពីប្រតិបត្តិការរបស់កម្មវិធី។

-ធានាឱ្យមានយន្តការ រចនាសម្ព័ន្ធ និងដំណើរការមួយ ដើម្បីវាស់វែង និងបង្ហាញពីគណនេយ្យភាពសម្រាប់លទ្ធផល

-ដាក់បញ្ចូលព័ត៌មានជាមូលដ្ឋានអំពីសុខភាពមនុស្សចាស់ ទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល (HIS)

-សុខដុមនីយកម្មសូចនាករ រួមបញ្ចូលទាំងការបំបែកទិន្នន័យ ទៅតាមកម្រិតថ្នាក់សង្គមសំខាន់ៗ (ឧទា. អាយុ ភេទ ប្រាក់ចំណូល រស់នៅជនបទ/ទីប្រជុំជន) និងវិធីសាស្ត្រប្រមូល និងវិភាគទិន្នន័យនៅទូទាំងវិស័យនានា។

<u>*ចំណុចដៅ៖*</u>

*-ទិន្នន័យដែលទាក់ទងនឹងសុខភាពមនុស្សចាស់ ដែលបែងចែកតាមប្រភេទ ត្រូវបានប្រមូលតាមរយៈប្រភពដែលអាចជឿទុកចិត្តបានមួយចំនួនរួមមាន ប្រព័ន្ធព័ត៌មានសុខាភិបាល(HIS) របាយការណ៍*

*នៅតាមមូលដ្ឋានសុខាភិបាលនិងការវាយតម្លៃដាក់លាក់ឧទា.មូលដ្ឋានទិន្នន័យឃុំ(CDB) ការអង្កេតប្រជាសាស្ត្រនិងសុខភាព (DHS) ការអង្កេតសង្គមនិងសេដ្ឋកិច្ចកម្ពុជា(CSES)។*

៤-១-៤ ធានាឱ្យមានការសិក្សាស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង

ការស្រាវជ្រាវស៊ីជម្រៅ នឹងជួយឱ្យយល់កាន់តែច្បាស់អំពីភ័ស្តុតាង ទាក់ទងនឹងបញ្ហាសុខភាពមនុស្សចាស់។ ជាអនុសាសន៍គឺត្រូវធានាឱ្យមាន ការសិក្សាស្រាវជ្រាវអំពីកត្តាហានិភ័យធំៗ នៅក្នុងជំងឺនានាដែលមានបន្ទុកខ្ពស់ ឧទា. ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម ជំងឺមហារីក និងជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃក៏ដូចជាការសិក្សានានា ដូចជាការអង្កេតKAP អំពីឥរិយាបថថែទាំសុខភាព ក្នុងចំណោមមនុស្សចាស់ ស្ថានភាពអាហារូបត្ថម្ភ និងរបៀបផ្តល់ចំណី និងរបៀបរស់នៅរបស់មនុស្សចាស់ ព្រមទាំងការវិភាគទិន្នន័យទីពីរទាក់ទងទៅនឹងមនុស្សចាស់ ដែលមានពីការអង្កេតជាតិដែលមានស្រាប់ ដូចជាការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា (CDHS)

-សិក្សាស្រាវជ្រាវអំពីកត្តាហានិភ័យធំៗ ដែលបណ្តាលឱ្យមានជំងឺ និងការស្លាប់ឆាប់ពេកក្នុងចំណោមមនុស្សចាស់ នៅក្នុងវិធីសាស្ត្រខ្សែជីវិត (life course approach) រួមទាំងប្រសិទ្ធភាពនៃអន្តរាគមន៍បង្ការ ថែទាំ និងស្តារលទ្ធភាពពលកម្ម និងថែទាំសម្រន់

-ផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មានដើម្បីជាមូលដ្ឋាននៃ ការតាក់តែងគោលនយោបាយ និងជំរុញអន្តរាគមន៍សុខភាព ប្រកបដោយប្រសិទ្ធភាពថែមទៀត។

*<u>ចំណុចដៅ៖</u>*

*-ព័ត៌មានត្រូវបានប្រមូលវិភាគ និងប្រើប្រាស់ដើម្បីកែលម្អការអភិវឌ្ឍ ការរៀបចំផែនការ និងការអនុវត្តអន្តរាគមន៍សុខភាពមនុស្សចាស់*

*-សូចនាករសុខភាពមនុស្សចាស់ដែលពាក់ព័ន្ធ ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលនិងសុខដុមនីយកម្មគ្រប់វិស័យ*

*-មជ្ឈមណ្ឌលឧត្តមភាពត្រូវបានបង្កើតឡើង និងមានដំណើរការដើម្បីគាំទ្រ អនុវត្តនិងសម្របសម្រួលការស្រាវជ្រាវអំពីសុខភាពមនុស្សចាស់។*

៤-១-៥ អភិវឌ្ឍន៍ធនធានមនុស្ស

គេត្រូវការការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលនៅគ្រប់កម្រិតថ្នាក់ នៅក្នុងការផ្តល់ការថែទាំសុខភាពប្រកបដោយគុណភាពដល់មនុស្សចាស់(បឋម កម្រិតទីពីរ និងទីបី) ទាំងនៅដំណាក់កាលមូលដ្ឋាន (នៅក្នុងសាលាបណ្តុះបណ្តាលគ្រូពេទ្យ សាលាបណ្តុះបណ្តាលគិលានុបដ្ឋាក ។ល។) និងការ បណ្តុះណ្តាលបន្ត (គ្រូពេទ្យថែទាំសុខភាពបឋម បុគ្គលិកសុខាភិបាលសហគមន៍ ។ល។) ដើម្បីធានាថាធនធានមនុស្ស មានសមត្ថភាពគ្រប់គ្រាន់ដើម្បីផ្តល់ការថែទាំចល័ត និងតាមផ្ទះប្រកបដោយគុណភាពក៏ដូចជាការថែទាំតាមស្ថាប័នរយៈពេលខ្លីនិងវែង។ ធាតុចូលសម្រាប់ការបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះបណ្តាលទាំងនេះមានលក្ខណៈខុសៗគ្នា ហើយត្រូវអភិវឌ្ឍឡើងផ្អែកតាមភាពចម្រុះផ្នែកវប្បធម៌និងសង្គម។ គេគួរបណ្តុះបណ្តាលវេជ្ជបណ្ឌិតឯកទេសផ្នែកជរាសាស្ត្រ និងការថែទាំមនុស្សចាស់ដើម្បីដំឡើងកម្រិតអប់រំនៅក្នុងប្រទេស។

ការលើកកម្ពស់សុខភាពរបស់មនុស្សចាស់ តាមរយៈការបណ្តុះបណ្តាលអ្នកផ្តល់ការថែទាំ និងអ្នក ផ្តល់សេវានៅសហគមន៍ អំពីសកម្មភាពរស់នៅប្រចាំថ្ងៃ លំហាត់ប្រាណ ការសង្គ្រោះបឋមជាមូលដ្ឋា ន និងការសម្គាល់សញ្ញាជំងឺទូទៅនៃជរាភាព ដើម្បីបញ្ជូនទៅរកសេវាថែទាំសុខភាព នឹងជួយធានាដល់ការថែទាំបន្តប្រកបដោយប្រសិទ្ធភាព។

-ធានាការយល់អំពីរបៀបឆ្លើយតបល្អបំផុតទៅនឹង តម្រូវការរបស់មនុស្សចាស់ ក្នុងចំណោមបុគ្គលិកសុខាភិបាល ដោយដាក់បញ្ចូលខ្លឹមសារពាក់ព័ន្ធទៅក្នុងកម្មវិធីសិក្សា នៃវិទ្យាសាស្ត្រសុខាភិបាលសម្រាប់ការអប់រំមូលដ្ឋាន និងការបណ្តុះបណ្តាលពេលកំពុងធ្វើការ

-បង្កើនភាពទាក់ទាញនៃជំនាញឯកទេសដែលពាក់ព័ន្ធ(ដូចជាជរាសាស្ត្រ និងវិជ្ជាថែទាំមនុស្សចាស់) និងផ្តល់ការថែទាំសុខភាពដល់មនុស្សចាស់ តាមរយៈការផ្សព្វផ្សាយ ការទទួលស្គាល់ ការលើកទឹកចិត្តនិងឱកាសការងារ

-ជំរុញការបណ្តុះបណ្តាលសម្រាប់ការថែទាំតាមផ្ទះ និងនៅសហគមន៍ អំពីតម្រូវការសុខភាពជាក់លាក់របស់មនុស្សចាស់ ទាក់ទងទៅនឹងការបង្ការ ការស្វែងរកការថែទាំ ការស្តារលទ្ធភាពពលកម្មនិងការថែទាំសម្រន់។

*<u>ចំណុចដៅ៖</u>*

*-កម្មវិធីសិក្សាត្រូវបានបង្កើតឡើង អនុម័ត និងអនុវត្ត ដោយមានការទទួលស្គាល់ជាផ្លូវការ*

*-បុគ្គលិកសុខាភិបាល មានចំណេះដឹងនិងជំនាញជាមូលដ្ឋាន ដើម្បីបំពេញតម្រូវការសុខភាពរបស់មនុស្សចាស់*

*-ចំនួនបុគ្គលិកសុខាភិបាលឯកទេស ដែលមានសមត្ថភាពជំនាញគ្រប់គ្រាន់ នៅកម្រិតថ្នាក់ពាក់ព័ន្ធនៃប្រព័ន្ធសុខាភិបាល។*

៤-១-៦ លើកកម្ពស់គម្រោងគាំពារសង្គម

ដើម្បីធានាសមធម៌នៅក្នុងការទទួលបាន ការថែទាំសុខភាពជាសារវ័ន្តជាបន្ត តាមរយៈគម្រោងគាំពារសង្គម នឹងត្រូវការការពង្រីកក្នុងចំណោមប្រជាជនវ័យចំណាស់។ ការរៀបចំផែនហិរញ្ញវត្ថុ នឹងត្រូវបានស្វែងរកដើម្បីធានាថា មនុស្សចាស់អាចទទួលបានការថែទាំ ឧទា. រួមទាំងការដឹកជញ្ជូន អ្នកអមដំណើរ ឱសថ និង បច្ចេកវិទ្យាជំនួយ។

-កំណត់ពីសេវាសុខភាពសារវ័ន្តសម្រាប់មនុស្សចាស់ ទាក់ទងនឹងការបង្ការ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងការព្យាបាលសម្រន់ រួមទាំងការថែទាំរយៈពេលវែង

-លើកកម្ពស់ការទទួលបាន សេវាសុខភាពសារវ័ន្តសម្រាប់មនុស្សចាស់ តាមរយៈការដាក់បញ្ចូលក្នុងគម្រោងគាំពារសង្គម ដូចជាមូលនិធិសមធម៌សុខភាព ការធានារ៉ាប់រងការគាំពារសង្គមរបស់ជាតិនិងការធានារ៉ាប់រងឯកជន។

*<u>ចំណុចដៅ៖</u>*

*-ការការពារពីហានិភ័យ ត្រូវបានកែលម្អដោយមនុស្សចាស់ទទួលបានអត្ថប្រយោជន៍ពីការគាំពារសុខភាពសង្គមគ្រប់ជ្រុងជ្រោយ រួមទាំងការទទួលបានសេវាសុខភាពសារវ័ន្ត។*

## ៥-ផែនការសកម្មភាព

## ៥-១ យន្តការស្ថាប័ន

ក្រសួងសុខាភិបាល មានអាណត្តិបង្កើតក្របខ័ណ្ឌបទដ្ឋាន សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធសេវាសុខភាពគ្រប់គ្រងសេវាសុខភាព និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃក៏ដូចជា ការផ្តល់សេវាថែទាំសុខភាពសាធារណៈ។

យន្តការស្ថាប័នដែលស្នើឡើងសម្រាប់ ការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់រួមមាន៖ មជ្ឈមណ្ឌលឧត្តមភាពជាតិមួយត្រូវបានប្រើប្រាស់ជាបង្អែក សម្រាប់ការថែទាំសុខភាពមនុស្សចាស់។ មជ្ឈមណ្ឌលនេះនឹងដាក់បញ្ចូលការថែទាំ ការបណ្តុះបណ្តាលនិងការស្រាវជ្រាវ ព្រមទាំងពិនិត្យមើលភាពពាក់ព័ន្ធ រយៈពេលខ្លី មធ្យម និងវែងនៃជរាភាពមកលើប្រព័ន្ធសុខាភិបាល សំដៅបង្កើនអាយុកាលរំពឹងទុកនិងកែលម្អគុណភាពជីវិតរបស់មនុស្សចាស់។ មជ្ឈមណ្ឌលនេះនឹងពិនិត្យមើលផងដែរ នូវទិដ្ឋភាពផ្សេងៗនៃការថែទាំរយៈពេលវែង និងការបណ្តុះបណ្តាលអំពីការថែទាំនៅសហគមន៍។

មន្ទីរពេទ្យជាតិនឹងផ្តល់សេវាថែទាំសុខភាពគ្រប់ជ្រុងជ្រោយដល់មនុស្សចាស់ រួមទាំងសេវាពិនិត្យសុខភាព ធ្វើរោគវិនិច្ឆ័យ ព្យាបាល និងស្តារលទ្ធភាពពលកម្ម។

មន្ទីរពេទ្យបង្អែក នឹងផ្តល់សេវាបង្ការកម្រិតទីពីរ តាមរយៈការពិនិត្យរកបញ្ហាសុខភាពទូទៅរបស់មនុស្សចាស់ដើម្បីធានាធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលទាន់ពេលវេលា ព្រមទាំងទប់ស្កាត់ផលវិបាក។ សេវាដែលផ្តល់នឹងរួមបញ្ចូលទាំងការផ្តល់ប្រឹក្សា និងការអប់រំអំពីកត្តាហានិភ័យផ្សេងៗ និងវិធានការជាមូលដ្ឋានទាក់ទងទៅនឹងការបង្ការ និងការថែទាំសម្រាប់ជំងឺទូទៅ និងកម្សោយចំពោះមនុស្សចាស់។

មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព នឹងផ្តល់សេវាថែទាំសុខភាពបង្ការបឋមសម្រាប់មនុស្សចាស់ នៅក្នុងតំបន់គ្របដណ្តប់ តាមរយៈការអនុវត្តសំណុំសកម្មភាពអប្បបរមា (MPA) ដែលរួមមាន៖ ការលើកកម្ពស់សុខភាព ការពិនិត្យរកជំងឺផ្សេងៗ ការផ្តល់ប្រឹក្សា ការពិនិត្យសុខភាព ព័ត៌មាន សេវាបញ្ជូន និងតាមដានបន្តសម្រាប់ការព្យាបាលដែលបានធ្វើឡើងនៅឯមន្ទីរពេទ្យបង្អែក។ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព នឹងផ្សារភ្ជាប់ជាមួយ ព្រមទាំងអនុវត្តគំនិតផ្តួចផ្តើមផ្សេងៗទៀត ដើម្បីពង្រីកសេវាសុខភាពសម្រាប់មនុស្សចាស់ លើសពីសេវា MPA ឧទា. តាមរយៈការពង្រីកសេវាលើកកម្ពស់សុខភាព សេវា ចុះមូលដ្ឋាន និងសេវានៅតាមសហគមន៍។ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព កត់ត្រា និងរាយការណ៍ អំពីបញ្ហាសុខភាព ការស្លាប់របស់មនុស្សចាស់។ នៅគ្រប់កម្រិតថ្នាក់ ប្រព័ន្ធសុខាភិបាលសហការជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងស្ថាប័នវិស័យឯកជន ដើម្បីលើកកម្ពស់ការថែទាំបន្ត និងកែលម្អសុខុមាលភាពរបស់មនុស្សចាស់នៅកម្ពុជា ដូចជា៖ ការិយាល័យមជ្ឈការ និងវិមជ្ឈការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឧទា. មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្ត (PRC) ការស្តារលទ្ធភាពនៅសហគមន៍ (CBR) ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរមូលដ្ឋានឧទា. ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (HCMC) ក្រុមទ្រទ្រង់សុខភាពភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ (VHSPG / VHV) សង្គមស៊ីវិលឧទា. សមាគមមនុស្សចាស់ ក្រុមគាំទ្រមិត្ត និងដៃគូអភិវឌ្ឍន៍ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

## ៥-២ ក្របខ័ណ្ឌច្បាប់

គោលនយោបាយនេះ មានដំណើរការនៅក្នុងក្របខ័ណ្ឌច្បាប់និងផែនការជាតិ ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការអន្តរក្រសួងសម្រាប់មនុស្សចាស់នៅកម្ពុជា ដែលមានក្រសួងសុខាភិបាលជាសមាជិក ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ និងគោលនយោបាយ គោលការណ៍ណែនាំពាក់ព័ន្ធនានា ដូចជាយុទ្ធសាស្ត្រជំងឺមិនឆ្លង និងមគ្គុទ្ទេសក៍សម្រាប់គ្រប់គ្រងជំងឺដាច់សរសៃឈាម ខួរក្បាល។

គោលនយោបាយ និងយុទ្ធសាស្ត្រនេះនឹងណែនាំដល់ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តអន្តរាគមន៍សុខភាព ប្រកបដោយប្រសិទ្ធភាពសម្រាប់មនុស្សចាស់។

នាយកដ្ឋានការពារសុខភាព ទទួលខុសត្រូវលើការរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីសុខភាពមនុស្សចាស់ ដោយសហការជាមួយនាយកដ្ឋានដទៃទៀត នៅក្នុងក្រសួងសុខាភិបាល មន្ទីរពេទ្យនៅគ្រប់កម្រិតថ្នាក់ ក្រសួងពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ឧទា. សមាគមមនុស្សចាស់ គំនិតផ្តួចផ្តើមគាំទ្រមិត្ត អ្នកស្ម័គ្រចិត្តសុខភាពភូមិ។

## ៥-៣ ការគាំទ្រផ្នែកហិរញ្ញវត្ថុ

ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់នៅក្នុងការផ្តល់ ការគ្របដណ្តប់សុខភាពសកលប្រកបដោយសមធម៌ដល់មនុស្សចាស់ទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ផែនការប្រតិបត្តិ ដែលមានតម្រូវការចំណាយថវិកា ក្នុងនោះនឹងត្រូវបានរៀបចំឡើងដោយនាយកដ្ឋានពាក់ព័ន្ធនៅក្នុង ក្រសួងសុខាភិបាល ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ ដើម្បីគាំទ្រដល់សំណើសុំថវិកាសម្រាប់អនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ទាក់ទងទៅនឹងសេវាបង្ការ ព្យាបាល ស្តារលទ្ធភាពពលកម្ម និងព្យាបាលសម្រន់ សម្រាប់មនុស្សចាស់និងការគ្រប់គ្រងប្រព័ន្ធដែលពាក់ព័ន្ធ។

ការដាក់បញ្ចូលសេវាបន្ថែម ដើម្បីលើកកម្ពស់សុខភាពមនុស្សចាស់ នឹងត្រូវការការវិនិយោគថវិកាបន្ថែមទៀត និងធ្វើការវិភាជចំណាយសាធារណៈកាន់តែច្រើនថែមទៀត សម្រាប់កែលម្អលទ្ធផលសុខភាពមនុស្សចាស់។ ឧទាហរណ៍ ការបង្កើនតម្រូវការសម្រាប់សេវាថែទាំរយៈពេលវែង អាចត្រូវបានគាំទ្រដោយការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដែលលើកទឹកចិត្តដល់ការដាក់បញ្ចូលសេវាពាក់ព័ន្ធ លើកកម្ពស់ការឆ្លើយតប និងជៀសវាងការប្តូរតម្រូវការចំណាយនៅក្នុង ប្រព័ន្ធសុខាភិបាល។ គេត្រូវស្វែងរកថវិកាពីប្រភពផ្សេងៗ ទាំងពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។

## ៥-៤ ការអភិវឌ្ឍធនធានមនុស្ស

ដើម្បីធានាថា គោលនយោបាយនេះមានប្រសិទ្ធភាព ស្ថាប័នអនុវត្តន៍គួរតែពិចារណាភាពពាក់ព័ន្ធរយៈពេលខ្លីនិងវែងនៃកម្មវិធីរបស់ពួកគេ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ឱ្យបានគ្រប់គ្រាន់។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សគួរតែផ្តោតគោលដៅលើ ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលបន្ត។ ផែនការអភិវឌ្ឍន៍ធនធានមនុស្សផ្អែកតាមតម្រូវការ គួរត្រូវបានរៀបចំឡើងដោយដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ដែលមានការទទួលស្គាល់គុណភាពផ្លូវការ សម្រាប់ប្រភេទផ្សេងៗនៃអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក៏ដូចជាការបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់សេវាថែទាំនៅសហគមន៍ និងតាមផ្ទះ

ដូចជា អ្នកស្ម័គ្រចិត្តភូមិ ឬសាច់ញាតិរបស់ពួកគេ។ ការទទួលស្គាល់ការបណ្តុះបណ្តាលគួរធ្វើឡើងតាម រយៈការទទួលស្គាល់គុណភាពជាផ្លូវការ (accreditation)។

**៥-៥ ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង** (IEC)

យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងគោលដៅ នឹងត្រូវបានបង្កើតឡើងសម្រាប់ធ្វើការផ្សព្វផ្សាយថ្នាក់ខ្ពស់ អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ភាគីពាក់ព័ន្ធក្នុងសហគមន៍ ការថែទាំតាមផ្ទះ(មនុស្សចាស់ អ្នកថែទាំ) និងប្រជាពលរដ្ឋទូទៅ។ ក្រសួងសុខាភិបាល តាមរយៈគណៈកម្មាធិការជាតិសម្រាប់សុខុមាលភាពមនុស្សចាស់ និងនាយកដ្ឋានការពារសុខភាព នឹងរួមចំណែកដល់ការផលិត និងចែកចាយសម្ភារៈអប់រំសុខភាព ដែលលើកកម្ពស់ជរាភាពប្រកបដោយសុខភាពល្អ នៅក្នុងបរិយាកាសដែលសមស្របតាមវ័យ។

**៥-៦ ការអនុវត្តគម្រោង**

គោលនយោបាយនិងយុទ្ធសាស្ត្រនេះ នឹងត្រូវបានណែនាំដោយដំណើរការរៀបចំផែនការ និងការអនុវត្តយោងទៅតាមវដ្តរៀបចំផែនការ ដែលដាក់បញ្ចូលនូវសមាសភាគទាំងឡាយដូចខាងក្រោមៈ ក)ការវិភាគស្ថានភាពមួយ ដែលផ្តល់ជាធាតុចូលសម្រាប់ ខ)ការរៀបចំដែលជាមូលដ្ឋានសម្រាប់ គ)ការគណនាតម្រូវការចំណាយ ព្រមទាំងគាំទ្រការកៀងគរធនធានឆ្ពោះទៅរក ឃ)ការអនុវត្ត ដែលនឹងត្រូវធ្វើការត្រួត ពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាការសម្រេចបានគោលដៅដែលបានកំណត់។

**៦-ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ**

ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ នឹងត្រូវបានធ្វើឡើងដោយផ្អែកលើសូចនាករជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពពាក់ព័ន្ធ និងមានពេលវេលាកំណត់ (SMART) ដែលផ្តោតលើប្រសិទ្ធភាពស្ថាប័ននិងផ្នែកប្រតិបត្តិការ។ ឧបករណ៍ដែលនឹងត្រូវបានយកមកអនុវត្តរួមមានរបាយការណ៍ទៀងទាត់ ការវាយតម្លៃស៊ីជម្រៅជាក់លាក់ និងសវនកម្មផ្ទៃក្នុង និងខាងក្រៅ។

ដោយសារតែទិន្នន័យស្តីពីស្ថានភាពសុខភាពមនុស្សចាស់មានកម្រិត ការដាក់បញ្ចូលសូចនាករមួយទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ អាចផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីអភិវឌ្ឍទិន្នន័យកាន់តែ គ្រប់ជ្រុងជ្រោយថែមទៀតដែលត្រូវប្រមូល យោងតាមគោលដៅលទ្ធផល សកម្មភាព និងការវិភាជថវិកានៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

សូចនាករដែលបានជ្រើសរើស អាចឆ្លុះបញ្ចាំងពីការប្រើប្រាស់សេវាសុខភាពដោយមនុស្សចាស់ (បន្តបែងចែកទៅតាមក្រុមអាយុរាល់៥ឆ្នាំ និងភេទ)។ ទិន្នន័យទាំងនេះអាចប្រមូលបានដោយងាយស្រួល សម្រាប់ធ្វើវិភាគនៅកម្រិតថ្នាក់ផ្សេងៗ នៃប្រព័ន្ធសុខាភិបាល ព្រមទាំងអនុញ្ញាតឱ្យមានការតាមដានជាបន្ត សំដៅឆ្ពោះទៅរកការកែលម្អសកម្មភាព។

សូចនាករបន្ថែមទៀតអាចរួមមានៈ ធនធានមនុស្ស សេវាដែលត្រូវបានដាក់បញ្ចូលក្នុងកញ្ចប់ភាគផលសុខភាព ព័ត៌មានអំពីមនុស្សចាស់ដែលត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល សហគមន៍ដែលមានការថែទាំតាមផ្ទះគ្រប់គ្រាន់សម្រាប់មនុស្សចាស់ជរា និងចំនួនសហគមន៍ដែលបានទទួលសារអំពីការលើកកម្ពស់និងអប់រំសុខភាព និងការថែទាំសុខភាពកម្រិតមូលដ្ឋានសម្រាប់មនុស្សចាស់។

## សន្ទានុក្រម

**Accessibility (ការទទួលបាន)**

រៀបរាប់អំពីកម្រិតនៃ ការទទួលបាននូវបរិស្ថានសេវាកម្មឬផលិតផលមួយ ដោយមនុស្សច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

**Active ageing (ជរាភាពសកម្ម)**

ដំណើរការនៃការបង្កើនឱកាសសម្រាប់សុខភាព ការចូលរួម និងសន្តិសុខ ដើម្បីលើកកម្ពស់គុណភាពជីវិត នៅពេលដែលមនុស្សចូលវ័យចំណាស់។

**Activities of daily living (ADLs) (សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ)**

សកម្មភាពជាមូលដ្ឋានដែលចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃដូចជា ការមុជទឹក ឬសំអាតខ្លួនប្រាណ ការស្លៀកពាក់ ការហូប ការងើបចេញពីគ្រែ ឬកៅអី ការប្រើបង្គន់ និងចលនាបំលាស់ទីជុំវិញផ្ទះ។

**Activity (សកម្មភាព)**

ការអនុវត្តកិច្ចការ ឬសកម្មភាពណាមួយដោយបុគ្គលណាម្នាក់។

**Age (chronological) (អាយុ) (ចំនួនអាយុដែលមនុស្សអាចរស់នៅបាន)**

ពេលវេលាដែលមនុស្សម្នាក់រស់នៅចាប់តាំងពីពេលកើត។

**Age-friendly cities and communities (ទីក្រុង និងសហគមន៍ដែលសមស្របតាមវ័យ)**

ទីក្រុង ឬសហគមន៍មួយ ដែលលើកកម្ពស់ជរាភាពប្រកបដោយផាសុកភាព និងភាពសកម្ម។

**Age-friendly environments (បរិស្ថានដែលសមស្របតាមវ័យ)**

បរិស្ថាននានា (ដូចជាផ្ទះ ឬសហគមន៍) ដែលលើកកម្ពស់ជរាភាពប្រកបដោយផាសុកភាព និងភាពសកម្មដោយកសាង និងថែរក្សាសមត្ថភាពខាងក្នុងនៅក្នុងខ្សែជីវិត និងជំរុញសមត្ថភាពផ្នែកមុខងារកាន់តែធំចំពោះបុគ្គលម្នាក់ ដែលមានសមត្ថភាពណាមួយ។

**Ageing (ជរាភាព)**

នៅឯកម្រិតថ្នាក់ជីវសាស្ត្រ ជរាភាព កើតចេញមកពីផលប៉ះពាល់នៃការកើតឡើងបន្តិចម្តងៗ នូវការខូចម៉ូលេគុល និងកោសិកា។

**Assistive technologies (បច្ចេកវិទ្យាជំនួយ)**

ឧបករណ៍នានាដែលត្រូវបានបង្កើត ផលិត ឬសម្របដើម្បីថែរក្សា ឬកែលម្អដំណើរការនិងសុខុមាលភាពរបស់បុគ្គល។

**Caregiver (អ្នកថែទាំ)**

បុគ្គលដែលផ្តល់ការថែទាំ និងការគាំទ្រដល់បុគ្គលម្នាក់ទៀត។ ការគាំទ្របែបនេះអាចរួមបញ្ចូលទាំងការជួយថែទាំដោយខ្លួនឯង កិច្ចការក្នុងផ្ទះ ភាពចល័ត ការចូលរួមក្នុងសង្គម និងសកម្មភាពប្រកបដោយ អត្ថន័យផ្សេងទៀត។

**Case management (ការគ្រប់គ្រងករណី)**

ដំណើរការសហការនៃការរៀបចំផែនការ សេវា និងការសម្របសម្រួលធនធានដើម្បីបំពេញតម្រូវការរបស់បុគ្គល តាមរយៈការប្រាស្រ័យទាក់ទងជាមួយបុគ្គល អ្នកជិតស្និទ្ធ និងអ្នកផ្តល់សេវា។

**Chronic condition (បញ្ហារ៉ាំរ៉ៃ)**

ជំងឺណាមួយ វិបត្តិ របួស ឬការប៉ះទង្គិចផ្លូវចិត្ត ដែលកើតឡើងដដែល ឬមានផលប៉ះពាល់រយៈពេលវែង។

**Comprehensive health services (សេវាសុខភាពគ្រប់ជ្រុងជ្រោយ)**

ជាការរួមបញ្ចូលនៃសេវាសុខភាព ឆ្ពោះទៅរកប្រសិទ្ធភាពកាន់តែប្រសើរ។

**Continuum of care (ការថែទាំបន្ត)**

វិសាលគមទាំងមូលនៃសេវាសុខភាពឯកទេស ស្តារលទ្ធភាពពលកម្ម និងលំនៅស្ថាន ដែលផ្តោតលើតម្រូវការផ្នែកសុខភាព ស្តារលទ្ធភាពពលកម្ម លំនៅស្ថាន សង្គម និងទ្រទ្រង់របស់បុគ្គលនានា។

**Disability (ពិការភាព)**

ពាក្យក្តោបជារួមសម្រាប់កម្សោយ ព្រំដែនកំណត់នៃសកម្មភាព និងកំហិតការចូលរួម ដោយសំដៅលើទិដ្ឋភាពអវិជ្ជមាននៃអន្តរកម្មរវាងបុគ្គល (ដែលមានបញ្ហាសុខភាពណាមួយ) និងកត្តាបរិបទរបស់បុគ្គលនោះ (កត្តាបរិស្ថាន និងផ្ទាល់ខ្លួន)។

**Effectiveness (ប្រសិទ្ធផល)**

ការសម្រេចបានលទ្ធផលល្អបំផុត។

**Efficiency (ប្រសិទ្ធភាព)**

ការសម្រេចបានលទ្ធផលល្អបំផុត ដោយចំណាយតិចបំផុត។

**Environments (បរិស្ថាន)**

កត្តាទាំងអស់នៅក្នុងពិភពខាងក្រៅដែលបង្កើតបរិបទនៃជីវិតរបស់បុគ្គលម្នាក់។ កត្តាទាំងនេះរួមមាន ផ្ទះ សហគមន៍ និងសង្គមទូទៅ។ នៅក្នុងបរិស្ថានទាំងនេះ គឺមានកត្តាជាច្រើន ដែលរួមមានបរិស្ថាន ដែលបានបង្កើតឡើង មនុស្ស និងទំនាក់ទំនងរបស់ពួកគេ លក្ខណសម្បត្តិនិងគុណតម្លៃ គោលនយោបាយសុខភាពនិងសង្គម ប្រព័ន្ធនិងសេវាកម្ម។

**Essential health services (សេវាសុខភាពសារវ័ន្ត)**

សេវាសុខភាពដែលមិនអាចខ្វះបាន សម្រាប់ការថែទាំសមស្របនៃកង្វល់សុខភាព ភាគច្រើនបំផុតនៅក្នុងចំណោមក្រុមប្រជាជនណាមួយ។

**Frailty (ទន់ខ្សោយ) (ឬមនុស្សចាស់ទន់ខ្សោយ frail older person)**

ភាពងាយរងគ្រោះយ៉ាងខ្លាំងចំពោះកត្តាសម្ពាធ ផ្លូវចិត្តខាងក្នុង និងខាងក្រៅ ដែលធ្វើឱ្យបុគ្គលម្នាក់ប្រឈមមុខនឹងលទ្ធផលសុខភាពអវិជ្ជមាន។

**Functional ability (សមត្ថភាពមុខងារ)**

លក្ខណសម្បត្តិដែលទាក់ទងនឹងសុខភាព ដែលជួយមនុស្សឱ្យធ្វើអ្វីដែលពួកគេមានហេតុផល ដើម្បីផ្តល់តម្លៃ។ វារួមផ្សំដោយសមត្ថភាពខាងក្នុងរបស់បុគ្គល ចរិតលក្ខណៈបរិស្ថានដែលពាក់ព័ន្ធ និងអន្តរកម្ម រវាងបុគ្គល និងចរិតលក្ខណៈទាំងនេះ។

**Functioning (មុខងារដែលមានដំណើរការ)**

ពាក្យក្តោបជារួមសម្រាប់មុខងាររាងកាយ រចនាសម្ព័ន្ធរាងកាយ សកម្មភាព និងការចូលរួម។ វាសំដៅលើទិដ្ឋភាពវិជ្ជមាននៃអន្តរកម្មរវាងបុគ្គល (ដែលមានបញ្ហាសុខភាពណាមួយ) និងកត្តាបរិបទរបស់បុគ្គល

នោះ (កត្តាបរិស្ថាន និងផ្ទាល់ខ្លួន)។

**Geriatrics (វិជ្ជាថែទាំមនុស្សចាស់)**

សាខានៃវេជ្ជសាស្ត្រ ដែលមានឯកទេសខាងសុខភាព និងជំងឺរបស់មនុស្សចាស់ និងការថែទាំ និងសេវាសមស្រប។

**Gerontology (ជរាសាស្ត្រ)**

ការសិក្សាអំពីទិដ្ឋភាពសង្គម ចិត្តសាស្ត្រ និងជីវសាស្ត្រនៃជរាភាព។

**Health (សុខភាព)**

ស្ថានភាពនៃសុខុមាលភាពពេញលេញផ្នែក ផ្លូវកាយ ផ្លូវចិត្ត និងសង្គម មិនត្រឹមតែភាពគ្មានជំងឺ ឬទុរ្ពលទ្រោមនោះឡើយ។

**Health characteristics (ចរិតលក្ខណៈសុខភាព)**

ការផ្លាស់ប្តូរទាក់ទងនឹងអាយុជាមូលដ្ឋាន ឥរិយាបថដែលទាក់ទងនឹងសុខភាព កត្តាហានិភ័យផ្នែកសរីរសាស្ត្រ (ឧទា-សម្ពាធឈាមខ្ពស់) ជំងឺ របួស ការផ្លាស់ប្តូរទៅលើសមតា និងចង្កោមរោគសញ្ញាចាស់ជរាទូលំទូលាយ អន្តរកម្មក្នុងចំណោមចរិតលក្ខណៈសុខភាពទាំងនេះ នឹងកំណត់ពីសមត្ថភាពខាងក្នុងរបស់បុគ្គលម្នាក់។

**Health condition (លក្ខខណ្ឌសុខភាព)**

ពាក្យក្តោបជារួមសម្រាប់ជំងឺស្រួចស្រាវ ឬរ៉ាំរ៉ៃ វិបត្តិ របួស ឬការប៉ះទង្គិចផ្លូវចិត្ត។

**Health inequality (វិសមភាពសុខភាព)**

ភាពខុសគ្នានៅក្នុងស្ថានភាពសុខភាព ដែលកើតឡើងក្នុងចំណោមបុគ្គល ឬក្រុម ឬជាផ្លូវការជាងនេះគឺបម្រែបម្រួលអន្តរបុគ្គលជារួមនៅក្នុងសុខភាព សម្រាប់ក្រុមប្រជាជនណាមួយ ដែលជារឿយៗ ពិចារណាពីភាពខុសគ្នានានានៅក្នុងស្ថានភាពសង្គមសេដ្ឋកិច្ច ឬចរិតលក្ខណៈផ្នែកប្រជាសាស្ត្រផ្សេងៗទៀត។

**Inequity (វិសមធម៌)**

ភាពខុសគ្នាដែលមិនចាំបាច់ អាចជៀសវាងបាន មិនស្មើភាព និងមិនយុត្តិធម៌។

**Health promotion (ការលើកកម្ពស់សុខភាព)**

ដំណើរការនៃការជួយមនុស្សឱ្យបង្កើនការគ្រប់គ្រងលើ និងកែលម្អសុខភាពរបស់ពួកគេ។

**Healthy Ageing (ជរាភាពប្រកបដោយផាសុកភាព)**

ដំណើរការនៃការអភិវឌ្ឍនិងថែរក្សាសមត្ថភាពផ្នែកមុខងារ ដែលលើកកម្ពស់សុខុមាលភាពចំពោះមនុស្សចាស់។

**Home modifications (ការកែប្រែផ្ទះ)**

ការប្តូរ ឬការសម្របនានាដែលធ្វើឡើងទៅលើលក្ខណៈពិសេស ផ្នែករូបវ័ន្តអចិន្ត្រៃយ៍នៃបរិស្ថានផ្ទះ ដើម្បីបង្កើនសុវត្ថិភាព ការចេញចូលជារូបវ័ន្ត និងផាសុកភាព។

**Impairment (កម្សោយ)**

ការបាត់បង់ ឬភាពខុសប្រក្រតីនៃរចនាសម្ព័ន្ធរាងកាយ ឬមុខងារសរីរសាស្ត្រ (រួមទាំងមុខងារផ្លូវចិត្ត)។

**Informal care (ការថែទាំក្រៅប្រព័ន្ធ)**

ការថែទាំដោយឥតគិតថ្លៃ ដែលផ្តល់ដោយសមាជិកគ្រួសារ មិត្តភក្តិ អ្នកជិតខាង ឬអ្នកស្ម័គ្រចិត្ត។

**Institutional care setting (បរិបទថែទាំក្នុងស្ថាប័ន)**

សំដៅលើស្ថាប័នដែលផ្តល់ការថែទាំរយៈពេលវែង។ ស្ថាប័នទាំងនេះអាចរួមមាន មជ្ឈមណ្ឌលសហគមន៍ មូលដ្ឋានរស់នៅដោយមានជំនួយ ផ្ទះថែទាំ មន្ទីរពេទ្យ និងមូលដ្ឋានសុខាភិបាលដទៃទៀត បរិបទថែទាំតាមស្ថាប័ន មិនត្រូវបានកំណត់ត្រឹមតែទំហំរបស់វានោះឡើយ។

**International Classification of Functioning, Disability and Health (ចំណាត់ថ្នាក់អន្តរជាតិ នៃមុខងារពិការភាព និងសុខភាព)**

ចំណាត់ថ្នាក់នៃសុខភាព និងសមាសភាគដែលពាក់ព័ន្ធនឹងសុខភាព ដែលពិពណ៌នាពីមុខងាររាងកាយ និងរចនាសម្ព័ន្ធ សកម្មភាព និងការចូលរួម។ សមាសភាគត្រូវបានធ្វើចំណាត់ថ្នាក់ពីទស្សនវិស័យផ្សេងៗ រាងកាយ បុគ្គល និងសង្គមពីព្រោះមុខងារនិងពិការភាពរបស់បុគ្គលកើតឡើងនៅក្នុងបរិបទមួយ ចំណាត់ថ្នាក់នេះរួមមានបញ្ជីកត្តាបរិស្ថាន។

**Intrinsic capacity (សមត្ថភាពខាងក្នុង)**

សមាសភាគនៃសមត្ថភាពផ្លូវកាយ និងផ្លូវចិត្តទាំងអស់ ដែលបុគ្គលម្នាក់មាន។

**Life-course approach (យុទ្ធវិធីខ្សែជីវិត)**

យុទ្ធវិធីនេះពិចារណាពីដំណើរការផ្នែកជីវសាស្រ្ត ឥរិយាបថ និងចិត្តសាស្រ្តជាមូលដ្ឋានដែលមានដំណើរការនៅទូទាំងខ្សែជីវិត ដែលត្រូវបានតម្រែតម្រង់ដោយចរិតលក្ខណៈនីមួយៗនិងដោយបរិស្ថានដែលយើងរស់នៅក្នុងនោះ។

**Life expectancy (at age 60) (អាយុកាលរំពឹងទុក) (នៅអាយុ ៦០ឆ្នាំ)**

ចំនួនឆ្នាំជាមធ្យមដែលមនុស្សអាយុ ៦០ឆ្នាំ ម្នាក់ អាចរំពឹងថានឹងរស់នៅ ប្រសិនបើគាត់ត្រូវស្ថិតនៅក្រោមអត្រាមរណភាពជាក់លាក់តាមអាយុ ក្នុងរយៈពេលជាក់លាក់មួយ។

**Life expectancy (at birth) (អាយុកាលរំពឹងទុកជាមធ្យម) (នៅពេលកើត)**

ចំនួនឆ្នាំជាមធ្យមដែលទារកទើបនឹងកើត ត្រូវបានរំពឹងថានឹងរស់នៅ ប្រសិនបើទារកនោះត្រូវស្ថិតក្រោមអត្រាមរណភាពជាក់លាក់តាមអាយុ ក្នុងរយៈពេលជាក់លាក់មួយ។

**Long-term care (ការថែទាំរយៈពេលវែង)**

សកម្មភាពដែលធ្វើឡើងដោយអ្នកផ្សេងទៀត ដើម្បីធានាថាអ្នកដែលបាត់បង់សមត្ថភាពខាងក្នុង អាចថែរក្សាកម្រិតនៃសមត្ថភាពមុខងារ ស្របតាមសិទ្ធិជាមូលដ្ឋានរបស់ពួកគេ សេរីភាពជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**Non-communicable diseases (ជំងឺមិនឆ្លង)**

ជំងឺដែលមិនឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតឡើយ។ ជំងឺមិនឆ្លងមានបួនប្រភេទចម្បងគឺជំងឺសរសៃឈាមបេះដូង (ដូចជា រោគគាំងបេះដូង និងជំងឺដាច់សរសៃឈាមខួរក្បាល) ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ (ដូចជា ជំងឺស្ទះសួតរ៉ាំរ៉ៃ និងហឺត) ជំងឺមហារីក និងជំងឺទឹកនោមផ្អែម។

**Older person (មនុស្សចាស់)**

មនុស្សដែលមានអាយុ ៦០ ឆ្នាំឡើងទៅ និងចំណាត់ថ្នាក់ជាពកម្រិតៈ

-ចាស់ ក្មេង (អាយុ ៦០-៦៩ឆ្នាំ)

-ចាស់ មធ្យម (អាយុ ៧០-៧៩ឆ្នាំ)

-ចាស់ ចាស់ (អាយុ ៨០ឡើង)។

**People-centered services (សេវាដែលផ្តោតលើមនុស្ស)**

យុទ្ធវិធីមួយចំពោះការថែទាំ ដែលប្រកាន់យកទស្សនវិស័យរបស់បុគ្គល គ្រួសារ និងសហគមន៍ និងចាត់ទុកពួកគេជាអ្នកចូលរួម ក៏ដូចជាអ្នកទទួលផលពីការថែទាំសុខភាព និងប្រព័ន្ធថែទាំរយៈពេលវែង ដែលឆ្លើយតបទៅនឹងតម្រូវការ និងចំណង់ចំណូលចិត្តរបស់ពួកគេ ជាលក្ខណៈមនុស្សធម៌ និងជារួម ដោយធានាថា សេវាដែលផ្តោតលើមនុស្សដែលផ្តល់ តម្រូវឱ្យមនុស្សមានការអប់រំ និងការគាំទ្រដែលពួកគេត្រូវការដើម្បីធ្វើការសម្រេចចិត្ត និងចូលរួមនៅក្នុងការថែទាំផ្ទាល់ខ្លួនពួកគេ។ សេវាទាំងនេះត្រូវបានរៀបចំឡើងជុំវិញតម្រូវការសុខភាព និងការរំពឹងទុករបស់មនុស្សជាជាងជំងឺ។

**Population ageing (ជរាភាពរបស់ប្រជាជន)**

ការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធប្រជាជន ដែលក្នុងនោះសមាមាត្រប្រជាជននៅក្នុងក្រុមអាយុចាស់កើនឡើង។

**Rehabilitation (ការស្តារលទ្ធភាពពលកម្ម)**

សំដៅលើសាខានៃវេជ្ជសាស្រ្ត ដែលមានគោលបំណងលើកកម្ពស់ ស្តារឡើងវិញ និងថែរក្សាសមត្ថភាពមុខងារល្អបំផុតនៅក្នុងចំណោមអ្នកដែលមានកម្សោយផ្លូវកាយ។

**Resilience (ភាពធន់)**

សមត្ថភាពដើម្បីថែរក្សា ឬលើកកម្ពស់កម្រិតនៃសមត្ថភាពមុខងារ នៅចំពោះមុខភាពមិនអនុគ្រោះតាម រយៈការតបត ការងើបឡើងវិញ ឬការសម្រប។

**Risk factor (កត្តាហានិភ័យ)**

កត្តាហានិភ័យគឺជាលក្ខណៈ ឬការប្រឈមដែលពាក់ព័ន្ធទៅនឹងភវនីយភាពនៃជំងឺ ឬរបួសកាន់តែច្រើន។

**Social protection (ការគាំពារសង្គម)**

កម្មវិធីដើម្បីកាត់បន្ថយការបាត់បង់ឱកាស ដែលកើតចេញពីលក្ខខណ្ឌនានា ដូចជាភាពក្រីក្រ ភាពគ្មានការងារធ្វើ អាយុចាស់ និងពិការភាព។

**Social security (សន្តិសុខសង្គម)**

រួមបញ្ចូលវិធានការទាំងអស់ដែលផ្តល់អត្ថប្រយោជន៍ ទោះជាសាច់ប្រាក់ ឬសម្ភារៈ ដើម្បីទទួលបានការគាំពារសង្គម។